# ករណីសិក្សាពីរស្តីពីទំលាប់នៃអំពើពុករលួយប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជា

*ករណីសិក្សាទាំងពីរដែលលើកយកមកបង្ហាញនៅទីនេះគឺជាផ្នែកមួយនៃគំរោងស្រាវជ្រាវមួយរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ (CSD) ដែលផ្តោតទៅលើអំពើពុករលួយនៅថ្នាក់ក្រោម ដែលមានចំណងជើងថា "ផលប៉ះពាល់ និងចរិកលក្ខណះនៃអំពើពុករលួយ" ដូចដែលការស្រាវជ្រាវបានពន្យល់អន្តរអំពើរវាងអំពើ ពុលរលួយ អំណាច និងភាពក្រីក្រ នៅក្នុងសម័យកាលកម្ពុជា ដូចដែលការសិក្សានេះបង្ហាញថា អំពើពុករលួយមិនមែនជាវប្បធម៌របស់កម្ពុជាទេ។ អត្ថបទខាងក្រោមគឺជាការសិក្សាដែលធ្វើឡើងដោយ កញ្ញា គ្រីស៊ីន នីសែន បំរើការនៅ CSD ទទួលបន្ទុកការងារផ្នែកសិក្សា អំពើពុករលួយ អំណាច និងភាពក្រីក្រនៅកម្ពុជា។ គំរោងនេះរួមបញ្ចូល ទាំងទំលាប់នៃអំពើពុករលួយ ដែលក្រុមគ្រួសារជួបប្រទះនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ នៅពេលដែលពួកគេធ្វើការទាក់ទង ជាមួយ ប៉ូលីស ទីផ្សារ សាលារៀន និងបណ្តាញដឹកជញ្ជូន គ្លីនិកសុខភាព អាជ្ញាធរពន្ធ មន្ត្រីអត្រានុកូលដ្ឋាន និងតុលាការ។ ដូចដែលការសិក្សា នេះលើក បង្ហាញអំពីស្ត្រីក្រីក្រដែលជួបប្រទះរាប់រយដំពូកនៅក្នុងជីវភាពប្រចាំថ្ងៃរបស់គាត់ ដោយប្រឈម ស្ថានប័ន រដ្ឋាភិបាលមូលដ្ឋាន និងការគ្រប់គ្រង របស់ថៅកែ។ ការភ័យខ្លាចចំពោះអ្នកមានអំណាច បានជំរុញអោយស្ត្រីបង្ខំចិត្តលក់ដី និងធ្វើអោយពួកគាត់ធ្លាក់ ទៅក្នុងភាពក្រីក្រ។ ភ័ព្វអាក្រក់ មុំទាំងបីនៃអំពើពុករលួយ អំណាច និងភាពក្រីក្រ ដែលស្ត្រីក្រីក្រជួបប្រទះនោះបានរារាំង ពួកគាត់មិនអោយមានលទ្ធភាពសំរាប់កែលំអជីវភាពប្រចាំថ្ងៃរបស់ពួកគាត់បាន។ លើសពីនេះ ដូចដែលករណីសិក្សាបាន បង្ហាញ អំពើពុករលួយនៅក្នុងវិស័យសេវាកម្មពីរដែលសំខាន់គឺការអប់រំ និងសុខាភិបាលនោះអាចជាផលវិបាកធ្ងន់ធ្ងរលើគ្រួសារអ្នកក្រ ដោយរួមទាំងបញ្ហាអនក្ខរភាព គ្មានឱកាសការងារ ជំងឺរុំារ៉ៃ និងការស្លាប់ក៏មាន។*

រយៈពេលជាង៤ខែ រស់នៅក្នុងទីរួមខេត្តតូចពីរក្នុងប្រទេសកម្ពុជា (ពីខែ មករា ដល់ខែ ឧសភា ឆ្នាំ ២០០៤) ខ្ញុំកត់សំគាល់ឃើញមានយោបល់លើកឡើងជាញឹកញាប់ស្តីអំពីអំពើពុករលួយ អំណាច និងភាពក្រីក្រ នៅក្នុងកិច្ចសន្ទនាប្រចាំថ្ងៃរបស់អ្នកភូមិជាច្រើន។ អ្នកជិតខាងជាច្រើនប្រមូលផ្តុំគ្នាដើម្បីជជែកអំពីការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ហើយបន្ទាប់មកពួកគេងាកទៅពិភាក្សាអំពីព្រឹត្តិការណ៍ថ្មីអំពីការិយាល័យធិបតេយ្យ ដូចជាៈ ថ្លៃសាំងខ្ពស់ ជំលោះបញ្ហាដីធ្លី ឬសមាជិកក្នុងគ្រួសារមានជំងឺ។ ជាដំបូងវត្តមានរបស់ខ្ញុំអាចមានឥទ្ធិពលលើការពិភាក្សា ក៏ប៉ុន្តែក្រោយមក ខ្ញុំបានដឹងថាពួកគេមិនពិភាក្សាលើបញ្ហាទាំងនេះទេ ដោយសារតែខ្ញុំចាប់អារម្មណ៍លើបញ្ហាទាំងនេះ ហើយដោយសារតែផលប៉ះពាល់លើជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ។


ថតដោយ : ប៊ុ សារឿន

ការសិក្សាវែកញែកទាំងពីរករណីនេះ បង្ហាញអំពីស្ថានភាពប្រក្រតីដែលស្ត្រីជួបប្រទះនៅក្នុងគ្រួសារក្រីក្រ។ ករណីទីមួយ គឺជាការធ្វើសំភាសន៏ជាក្រុមជាមួយស្ត្រីក្រីក្រចំនួន ១៩ នាក់ ដោយប្រើវិធីសាស្ត្រវាយតំលៃតាមបែបគុណភាពដែលមានការចូលរួម របស់ធនាគារពិភពលោក អំពីអំពើពុករលួយ ដែលមានចំនងជើងថា អ្នកក្រត្រូវហ៊ាននិយាយៈ រឿងពុករលួយ ១៧ យ៉ាង ដែលសរសេរដោយ លោក Rathi Hardjono និង Stefanie Teggemann (Eds.)។ ស្ត្រីបានពិភាក្សាគ្នាអំពីបញ្ហាប្រចាំថ្ងៃរបស់ខ្លួន បានបង្ហាញអំពីស្ថាប័ន នានាដែលពួកគាត់បង់ប្រាក់សំណូក បានជ្រើសរើសស្ថាប័នដែលពួកគាត់បានបង់ប្រាក់សំណូក ដែលជាបញ្ហាធំជាងគេបំផុត និងគូសបញ្ជាក់អំពីបុព្វហេតុ និងផលប៉ះពាល់នៃការបង់ប្រាក់សំណូកទៅអោយស្ថាប័នទាំងនោះ។ ករណីទីពីរ គឺផ្អែកលើការធ្វើសំភាសន៏មួយ ជាមួយនិងស្ត្រីម្នាក់ដែលជួបប្រទះបញ្ហាដែលទាក់ទងទៅនឹងភាពក្រីក្រធ្ងន់ធ្ងរ ព្រោះគាត់បានបាត់បង់ដីដោយសារមនុស្សមានអំណាច បន្ទាប់មកទៀតប្តីរបស់គាត់បានស្លាប់ចោល និងពេលថ្មីៗនេះកូនពៅរបស់ គាត់បានស្លាប់ចោលទៀត។ សព្វថ្ងៃនេះគាត់គ្មានផ្ទះនៅទេ។ គាត់មានការលំបាកក្នុងការចិញ្ចឹមកូនរបស់គាត់ផ្សេងទៀត ហើយគាត់ជំពាក់បំណុលគេដោយសារគាត់បានចំណាយលុយលើថ្នាំពេទ្យ និងថែទាំសុខភាពរបស់កូនពៅគាត់ដែលបានស្លាប់ទៅនោះ។

ខ្ញុំសង្កេតឃើញថា ប្រជាជនកម្ពុជាជាច្រើន ទោះបីជាពួកគេមិនចេះអក្សរ និងខ្វះការអប់រំជាផ្លូវការក្តី ក៏ពួកគេមានគំនិតរឹងត្អឹង អំពីហេតុផលចំពោះអំពើពុករលួយដែរ គ្រាន់តែថាពួកគេខ្វះមធ្យោបាយទប់ទល់ទៅនឹងទំលាប់នេះ។

## ករណី ១: ពីការពិភាក្សាជាក្រុម

ខ្ញុំបានរៀបចំការប្រជុំជាក្រុមមួយជាមួយស្ត្រីក្រីក្រចំនួន ១០នាក់ នៅក្នុងសហគមន៍ដែលខ្ញុំរស់នៅ។ យើងជួបជុំគ្នានៅផ្ទះទំនេរមួយដែលមានស្ត្រីក្មេងម្នាក់និងប្តីរបស់នាងនៅចាំយាម។ ដីនិងផ្ទះនោះជាកម្មសិទ្ធិរបស់អ្នកនៅទីក្រុងភ្នំពេញ ក៏ប៉ុន្តែ គ្រួសារ នេះរស់នៅដោយប្រកបរបរលក់ផ្លែឈើដែលដាំនៅក្នុងចំការ។ ខ្ញុំបានផ្សព្វផ្សាយថា មានអំណោយបន្តិចបន្តួចសំរាប់អ្នកមកចូលរួម ព្រោះការប្រជុំនេះនឹងមានរយៈពេលច្រើនម៉ោង។ ខ្ញុំមានការភ្ញាក់ផ្អើល ព្រោះមានស្ត្រីចំនួន ១៩នាក់ និងកូន៧របស់ពួកគាត់បានមកចូលរួមក្នុងអង្គប្រជុំ។ ពាក្យចរចាមអារាមថាមានអំណោយបានទាក់ទាញប្រពន្ធនិងបងប្អូនស្រីរបស់អ្នកជិតខាងទាំងអស់មកចូលរួម។ សមាជិកក្រុមប្រឹក្សាឃុំម្នាក់ក៏មានវត្តមាននៅក្នុងអង្គប្រជុំនេះដែរ ដើម្បីធ្វើរបាយការណ៍ជូនប្រធានឃុំអំពីបញ្ហានានាដែលបានលើកយកមកពិភាក្សា។ ក៏ប៉ុន្តែ កិច្ចប្រជុំនេះ ហាក់ដូចជាគ្មានប្រសិទ្ធិភាពច្រើនលើអ្វីដែលស្ត្រីនិយាយទេ ហើយខ្ញុំសប្បាយចិត្ត ដោយឃើញសមាជិកក្រុមប្រឹក្សាឃុំក៏ចូលរួមក្នុងការពិភាក្សានេះផងដែរ។

ក្រុមស្ត្រីតំណាងអោយក្រុមគ្រួសារនានាដែលធ្វើស្រែ ចិញ្ចឹមត្រី ធ្វើជាកម្មករដាំដុះប្រចាំថ្ងៃ ឬលក់នំ ផ្លែឈើ ឬក៏បង្អែមនៅ តាមដងផ្លូវ។ ស្ត្រីភាគច្រើនមានកូនពី ៥ ទៅ ១០ នាក់ ហើយកូនពួកគាត់ភាគច្រើនមិនបានចូលរៀនទេ។ ស្ត្រីទាំងនោះបានពន្យល់ថា ជាញឹកញាប់កូនក្មេងទាំងនេះមិនចូលសាលាទេពីព្រោះពួកវារៀនមិនទាន់គេ ឬដោយសារតែគ្រួសាររបស់ពួកវាគ្មានលទ្ធភាពបង់លុយអោយវាចូលរៀន ឬក៏គ្មានលុយអោយកូនសំរាប់ទិញនំចំណីញ៉ាំនៅឯសាលា។

យើងចាប់ផ្តើមពិភាក្សាមួយជុំ ដោយអោយស្ត្រីទាំងអស់រៀបរាប់អំពីបញ្ហាទូទៅរបស់ខ្លួន។ ស្ត្រីក្មេងម្នាក់បានរៀបរាប់ប្រាប់ថា គាត់ចង់បានការងារធ្វើដើម្បីបានលុយសំរាប់ចិញ្ចឹមគ្រួសាររបស់គាត់។ ក៏ប៉ុន្តែ ដើម្បីបានការងារធ្វើដំបូងគាត់ត្រូវការលុយ សំរាប់សូកប៉ាន់គេ តែគាត់គ្មាន។ គាត់បាននិយាយថា:

> "ខ្ញុំរកការងារមិនបានធ្វើ ពីព្រោះខ្ញុំគ្មានលុយ។ ខ្ញុំរកការងារមិនបានធ្វើ ពីព្រោះខ្ញុំជាស្រី។"

ស្ត្រីក្មេងម្នាក់ទៀតបានបន្ថែមថា:

> "ខ្ញុំមិនអាចរកការងារបានធ្វើទេ។ ខ្ញុំរៀនចប់ថ្នាក់វិទ្យាល័យ ក៏ប៉ុន្តែ ចាំបាច់ត្រូវតែបង់ថ្លៃសំណូក ទើបបានធ្វើជាគ្រូ បង្រៀន។ ខ្ញុំគ្មានលុយសូកទេ។"

ស្ត្រីចំណាស់ម្នាក់អង្គុយក្បែរនោះបានងក់ក្បាលយល់ស្រប។ មានការឯកភាពគ្នាជាទូទៅថា វាគ្មានហេតុផលអ្វីដែលត្រូវអោយ កូនគាត់ទៅរៀនទេ ជាពិសេសចំពោះកូនស្រី ពីព្រោះពួកគាត់ក្រីក្រ ហើយនឹងរកការងារមិនបានធ្វើទេ សូម្បីតែមានចំណេះ ដឹងហើយក៏ដោយ។

ខ្ញុំបានស្នើសុំអោយពួកគេសរសេរឈ្មោះស្ថាប័នទាំងអស់នៅក្នុងតំបន់នោះ។ ស្ត្រីក្មេងម្នាក់ក្នុងចំណោមស្ត្រីទាំងអស់ជាអ្នកសរសេរ ចំណែកឯស្ត្រីដទៃផ្សេងទៀត ជាអ្នកប្រាប់ឈ្មោះស្ថាប័នទាំងនោះម្តងមួយ។ ពួកគេសរសេរបានចំនួន ២៣ ស្ថាប័ន។ បន្ទាប់មក ពួកគេសរសេរនៅលើក្រដាសតូចៗ នូវចំនួនទឹកប្រាក់ដែលពួកគេបានសូកប៉ាន់កាលពីឆ្នាំកន្លងទៅ ហើយភ្ជាប់មកជាមួយនូវលិខិតបង់ប្រាក់ដែលស្ថាប័ននិមួយៗបានចេញអោយផង។ បន្ទាប់មក យើងព្យាយាមចងស្គាល់ស្ថាប័នទាំងអស់នោះ ដែលពួកគាត់មានអារម្មណ៍គិតថាបានបង់ប្រាក់ខុសច្បាប់ បណ្តាលអោយមានបញ្ហាធំកើតឡើង។ ស្ត្រីម្នាក់ជ្រើសរើសស្ថាប័នពីរ ដោយប្រើដុំថ្ម។ លទ្ធផលបង្ហាញយ៉ាងច្បាស់។ ស្ត្រីមានការព្រួយបារម្ភជាពិសេសអំពីការបង់ប្រាក់ខុសច្បាប់នៅឯមន្ទីរពេទ្យ (៦៤%) និងបង់ទៅប៉ូលីស (៣០%)។ ស្ត្រីមួយចំនួនទៅពិគ្រោះជំងឺនៅមន្ទីរពេទ្យកាលពីឆ្នាំកន្លងទៅ ហើយពួកគេបានបង់ លុយស្របច្បាប់ចំនួន ៤០,០០០ រៀល ផងនិងលុយក្រៅផ្លូវការបន្ថែមទៀតទៅអោយវេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកា ដើម្បី ទទួលបានការព្យាបាល។ ចំពោះមូលហេតុនេះ ស្ត្រីភាគច្រើនជ្រើសរើសយកគ្លីនិកឯកជនដើម្បីពិគ្រោះជំងឺជំនួសវិញ ប៉ុន្តែ ពួកគេបាននិយាយថា គ្រូពេទ្យនៅគ្លីនិកឯកជនទាំងនោះគឺជាមនុស្សតែមួយដែលធ្វើការនៅមន្ទីរពេទ្យ។

យើងពិភាក្សាអំពីការជ្រើសរើសនិងមូលហេតុនានាដែលពួកគេចាំបាច់ត្រូវបង់ប្រាក់ក្រៅផ្លូវការនេះ។ ស្ត្រីម្នាក់បានបញ្ជាក់អំពីមូលហេតុដែលស្ត្រីដទៃទៀតយល់ព្រមបង់ប្រាក់សំណូកទៅអោយបុរស គឺដោយសារតែបុរសត្រូវការលុយសំរាប់ទិញស្រាបៀរ និងទៅរកស្រីបន។ ពួកគេក៏បានបញ្ជាក់ផងដែរថា បុរសមួយចំនួនត្រូវប្រពន្ធរបស់ខ្លួនដាក់កំហិតអោយយកលុយទៅផ្ទះ ដើម្បី អោយប្រពន្ធទិញគ្រឿងអលង្ការ។



## ករណីសិក្សាទី២ : ម្តាយដែលគ្មានដីធ្លី


ថតដោយ ផាំង វីរប៉ុ

ខ្ញុំបានជួបអ្នកស្រី ម៉ុន តាមរយៈអ្នកបកប្រែ។ អ្នកស្រីជាស្ត្រីមានកំពស់ខ្ពស់បែបខ្មែរ សក់ខ្មៅរួញអង្កាញ និងមានអាយុប្រហែលជាង ៣០ ឆ្នាំ។ ឪពុក របស់អ្នកស្រីត្រូវបានគេសំលាប់ក្នុងឆ្នាំ ១៩៧៥។ បន្ទាប់ពីបញ្ចប់របបប៉ុលពត នាឆ្នាំ ១៩៧៩ អ្នកស្រីបានទៅរស់នៅភូមិមួយនៅឯខេត្តកំពត។ នៅទីនោះ ម្តាយរបស់អ្នកស្រីមានដីមួយកន្លែងនៅតាមមាត់ឆ្នេរដែល អាចអោយពួកគាត់ប្រកបរបរចិញ្ចឹមជីវិតតរៀងមក។ អ្នកស្រីរស់នៅជាមួយម្តាយ ប្តី និងកូនៗ។ នៅឆ្នាំ ១៩៩០ ម្តាយរបស់អ្នកស្រីបានលក់ដីនោះ ព្រោះពួកគាត់ខ្លាចបាត់បង់ ដីនោះ ទៅអ្នកមានអំណាច :

> "យើងខ្លាចដីរបស់យើងបាត់បង់ ប្រសិនបើយើងមិនលក់ទេ មេស្រុកយកដីនោះដោយគ្មានអោយកំរៃអ្វីឡើយ។ ពួកយើងភ័យខ្លាចពីព្រោះគេមានអំណាច។ ពួកគេ (មេស្រុក) បាននិយាយថា ប្រសិនបើពួកយើងមិនលក់ ពួកគេត្រូវតែ យកដីនោះមកទទេ។ ប៉ុន្តែប្រសិនបើយើងព្រមលក់ យើងបានលុយបន្តិចបន្តួចដើម្បីទិញរបស់របបរហូបចុកបន្តទៀត។ មួយ វិញទៀត យើងអាចរស់នៅទីនេះ បន្តរហូតដល់ម្ចាស់ថ្មីនេះគេត្រូវការដីវិញ "។

អ្នកជិតខាងមួយចំនួនបានបាត់បង់ដី ដោយគ្មានការសងជំងឺចិត្ត (សំណង) ហើយពេលខ្លះជនប្រដាប់អាវុធគំរាម កំហែងក្រុមគ្រួសារអោយចាកចេញពីដីដែលជាកម្មសិទ្ធិប្រជាជន។ ក្រុមគ្រួសារនោះ ពុំហ៊ានតវ៉ាប្រថុយជីវិតជាមួយពួកនេះទេ។ ពួកគេរស់នៅលើដីនោះ បន្ទាប់ពីបានលក់អោយម្ចាស់ថ្មីហើយ ហើយគ្មានបង់លុយកាក់អ្វីទាំងអស់។ កាលពី ៣ខែមុន ម្ចាស់ថ្មីបានប្រាប់ពួកគេអោយចាកចេញ។ ដោយគាត់ជំរាបថាគាត់បានលក់ដីនោះអោយទៅអ្នកថ្មីទៀតហើយ។

ប្តីរបស់អ្នកស្រី ម៉ុន បានស្លាប់កាលពី ៦ឆ្នាំមុន ដោយបន្សល់ទុកនូវកូនចំនួន ០៤នាក់ និងម្តាយ ចាស់ជរា នៅក្នុងបន្ទុក។ លុយកាក់ដែលមាននៅពេលនោះបានចាយវាយទៅលើការព្យាបាលជំងឺប្តី ហើយវាមិនគ្រប់គ្រាន់សំរាប់ សង្គ្រោះប្តីអោយរស់រានមានជីវិតទេ។ បងស្រីស្គាល់នាយកសាលាម្នាក់ ហើយបានអោយកូនប្រុសច្បងទៅគាត់ ដូចនេះកូនគាត់ ត្រូវបានលោកនាយកមើលថែរក្សា និងចិញ្ចឹមបីបាច់។ អ្នកស្រីបានពន្យល់ខ្ញុំថា ការធ្វើបែបនេះ កើតមានច្រើនណាស់ ចំពោះ កម្ពុជា ពីព្រោះពួកគេខ្វះខាត។ កូនប្រុសច្បងនោះអាយុ ១៦ឆ្នាំហើយ ពេលនេះរៀនថ្នាក់ទី ៦។ អ្នកស្រីនៅមានកូន ០៣នាក់ទៀត ហើយពួកគេទាំងអស់មិនបានចូលរៀនទេ។ បងស្រី និយាយថា គាត់គ្មានលទ្ធភាពអោយពួកគេរៀនបានទេ ពីព្រោះពួកគេ ត្រូវការលុយទិញអ្វីញុំានៅឯសាលា ដែលលក់ដោយលោកគ្រូអ្នកគ្រូ។ កូនទាំង ០៣នាក់នោះ អាចចាយម្នាក់ៗ ពី ២០០ ទៅ ៣០០ រៀល ក្នុងមួយថ្ងៃៗ ដូចនេះគាត់ត្រូវចំណាយ ៧០០រៀល ក្នុងមួយថ្ងៃ។

យើងបានអង្គុយនៅក្នុងខ្ទមតូចដាច់ផ្ទះឆ្ងាយ ដែលប្រក់ស្លឹកត្នោត។ អ្នកស្រីអង្គុយលើគ្រែ ខ្ញុំអង្គុយលើកៅអីជ័រ ដែលខ្ចីពីផ្ទះ អ្នកជិតខាង។ អ្នកស្រីបានប្រាប់ខ្ញុំថា គាត់មករស់នៅទីនេះ ចាប់តាំងគេដេញគាត់ចេញពីដីរបស់គាត់មកម្លេះ។ ដីដែលគាត់រស់ នៅជា កម្មសិទ្ធិរបស់សាលា ប៉ុន្តែនាយកសាលាអនុញ្ញាតអោយគាត់នៅដោយសារ ពុំមានកន្លែងណាសំរាប់រស់នៅទេ។ គាត់មិនអាចដាំដុះ បន្លែបង្កា សំរាប់ក្រុមគ្រួសារ ឬលក់ដូរនោះទេ ពីព្រោះគាត់មិនដឹងពេលណា គាត់នឹងចាកចេញ នោះទេ។

ប្រហែលជា ពីរ ឬ ៣ឆ្នាំមុន អ្នកស្រី ម៉ុន បានរៀបការជាមួយបុរសម្នាក់ដែលរស់នៅជិតនោះ ក្នុងនាមជាប្រពន្ធទី ២ :

> "វាជារឿងកំសត់មួយមិនគួរនឹកនាទេ ប៉ុន្តែគាត់បានជួយទិញឈើដើម្បីសាងសង់ខ្ទមនេះ ហើយបានផ្តល់ចំណីអាហាររហូតមកដល់ពេលនេះ។ ខ្ញុំមានកូន ម្នាក់ជាមួយគាត់ ប៉ុន្តែកូននោះបានស្លាប់ ១ខែ ៥ថ្ងៃ មកហើយ។ ឥឡូវ ខ្ញុំជំពាក់លុយគ្លីនិកឯកជន ព្រោះព្យាបាលកូនខ្ញុំ "។

និយាយដង់ត្រឹមនេះទឹកភ្នែករបស់អ្នកស្រីចាប់ផ្តើមហូរចេញមក។ អ្នកស្រីពុំមានការសប្បាយរីករាយរស់នៅជាប្រពន្ធទី ២ និងទទួលរងទុក្ខយ៉ាងធ្ងន់ធ្ងរពីទំនាក់ទំនងបែបនេះទេ។ ប៉ុន្តែស្ត្រីដែលរស់នៅម្នាក់ឯង ជាមួយកូនតូចៗ ០៣នាក់ ងាយរងគ្រោះ ការមាក់ងាយ និងទទួលការគំរាមគំហែងណាស់ ដូច្នេះបងស្រីសំរេចចិត្តរៀបការដើម្បីបានប្តីជារណាំងជួយការពារ ទោះបីជាបុរសនោះមកម្តងម្កាលក៏ដោយ។

វិជ្ជបណ្ឌិតដែលព្យាបាលកូនរបស់គាត់ដែលឈឺនៅឯក្លីនិកឯកជននោះ ក៏ជាពេទ្យធ្មប និងជាសមាជិក ក្រុមប្រឹក្សា ឃុំដែរ។ អ្នកស្រី ម៉ុន ពន្យល់ថា បងស្រីបានទៅមន្ទីរពេទ្យ នាំកូនឈឺទៅព្យាបាល ប៉ុន្តែបងស្រី មានតែ ២៥,០០០ រៀល។ ដូច្នេះកូនគាត់មិនអាចព្យាបាលបានទេ ដោយគេទារលុយ ៤០,០០០ រៀល។ បងស្រីបានពិភាក្សាជាមួយក្លីនិកឯកជនកន្លែង ដែលគាត់មិនបាច់បង់លុយមុន ហើយអាចបង់បន្តិចម្តងៗ ឬក៏បង់ជាកំរៃពលកម្មទៅធ្វើការនៅទីនោះ។ អ្នកស្រី ម៉ុន ពន្យល់ថា :




> “នៅឯមន្ទីរពេទ្យ ពួកគេនិយាយថា កូនខ្ញុំពិបាកព្យាបាលណាស់។ ពួកគេនិយាយបែបនេះ ដោយសារខ្ញុំគ្មានលុយ ដូច្នេះពួកគេមិនចង់ព្យាបាលកូនខ្ញុំទេ”។

អ្នកស្រី ម៉ុន មានអារម្មណ៍ថាគាត់ គ្មានអំណាច និងបាត់បង់អ្វីៗទាំងអស់អំពីអនាគត និងមិនដឹងថាសភាពការណ៍ប្រែប្រួលយ៉ាងណាទេ។ គាត់ប្រាប់ខ្ញុំថា នៅពេលដែលគាត់គ្មានម្ហូបអាហារសំរាប់ចិញ្ចឹមកូនៗ គាត់បានអង្គុយតាមផ្លូវសង្ឃឹមថាមានសប្បុរសជនធ្វើដំណើរបោះនូវម្ហូបអាហារ ឬលុយកាក់អោយគាត់។ ជារឿយៗ បងស្រី ម្នាក់ដែលនៅជិតខាងនោះ យកបាយមកអោយកូនៗគាត់ហូប។ ពេលខ្លះអ្នកស្រីបានអង្កពីបងប្រុសរបស់គាត់ ដែលរស់នៅ ប្រមាណជា ៣០ គ.ម ពីគាត់។ ពេលទៅដល់ខ្ទមគាត់ ខ្ញុំឃើញថាគាត់គ្មានបាយនិងអង្កទេ ហើយគាត់ក៏មិនដឹងពេលណាមាន ឬធ្វើយ៉ាងណាដែលអាចអោយគាត់បង់ប្រាក់ជំពាក់គ្លីនិកឯកជនបាននោះបានដែរ។

អ្នកស្រី ម៉ុន មានការគោរពរាប់អាននៅក្នុងសហគមន៍ ប៉ុន្តែស្ថានភាពរបស់គាត់នៅទាប ដោយសារ គាត់គ្មាន ទុនសេដ្ឋកិច្ច ឬសង្គម។ គាត់រំពឹងថានឹងធ្វើការអោយសាលា និងគ្លីនិកឯកជន នៅពេលណាដែលពួកគេត្រូវការ ប៉ុន្តែដោយ សារតែគាត់ជំពាក់គេដូចនេះគាត់គ្មានកំរៃទេ។ ពួកគេហាក់ដូចជាអ្នកត្រួតត្រា ហើយគាត់ត្រូវគោរពឱនលំទោន និងធ្វើអ្វីតាមគេបញ្ជា ដូចគ្នាដែរជាមួយប្តីរបស់គាត់។ ទំនាក់ទំនងបែបត្រួតត្រាទាំងនេះ ធ្វើអោយអ្នកស្រី ម៉ុន បាត់បង់ឱកាសសំរាប់រើខ្លួនចេញពីភាពក្រីក្រ។

មុនខ្ញុំចាកចេញពីអ្នកស្រី ម៉ុន គាត់បានប្រាប់ខ្ញុំថា គាត់បានសុបិន្តឃើញទៅស្រុកបារាំង ថ្ងៃណាមួយមិនខាន។

## សេចក្តីសន្និដ្ឋាន :

អំពើពុករលួយ អំណាច និងភាពក្រីក្រ គឺមានទំនាក់ទំនងគ្នា ទៅវិញទៅមកហើយមិនអាចដោះស្រាយដាច់ដោយឡែកពីគ្នាបានទេ។ ទង្វើនៃអំពើពុករលួយគឺជាផ្លូវមួយនៃការយកលុយពីអ្នកក្រអោយអ្នកមានដែលបង្កអោយមានការកើន ឡើងគំលាតរវាងអ្នកមាននិងអ្នកក្រ ហើយជាសង្គមមួយដែលមានរចនាសម្ព័ន្ធមិនផ្លូវការគ្រប់គ្រងស្ថាប័នផ្លូវការ។ បញ្ហានេះធ្វើអោយប៉ះពាល់ដល់ជីវិតរស់នៅរបស់សង្គមកម្ពុជា។

កញ្ញា គ្រីស្ទីណា នីសែន អ្នកសំរបសំរួលការស្រាវជ្រាវ

មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍សង្គម

**សិក្សាដោយ:**

មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម

**ឧបត្ថម្ភដោយ:**

diakonia ដាយកូនៀ

ធនាគារពិភពលោក

ជំនួយព្រះវិហារដាន

ស្ថានទូតដាណឺម៉ាកប្រចាំបាងកក